ឯកសារស្តីពីប្រវត្តិសាស្ត្រខ្មែរនាចុងសតវត្សទី១៩ និងសតវត្សទី២០ ដែលអ្នកស្រាវជ្រាវបរទេសក្តី ខ្មែរក្តី បានបោះពុម្ពផ្សាយកន្លងមក ភាគច្រើនបង្ហាញអំពីប្រវត្តិសាស្ត្រ "ផ្លូវការ" ពោលគឺសរសេរសំដៅលើព្រឹត្តិការណ៍ដែលគេយល់ថាសំខាន់ៗប៉ុណ្ណោះ។ តែបើយើងចង់ដឹងពីរឿងរ៉ាវដែលកើតឡើងរៀងរាល់ថ្ងៃនៅក្នុងជីវិតមនុស្សម្នាក់ៗ និងការពិសោធន៍ផ្ទាល់របស់គេ សៀវភៅ ឬឯកសាររបៀបផ្លូវការទាំងនោះកម្រឲ្យយើងដឹងណាស់។ ពោលដូច្នេះពុំមានន័យថា ឯកសារសរសេរជាកាសែតក្តី ជាសៀវភៅក្តី មិនមានប្រយោជន៍នោះទេ ប៉ុន្តែវាមិនអាចផ្តល់ពត៌មានឲ្យបានក្បោះក្បាយ។ ឧទាហរណ៍នៅឆ្នាំ១៩៤៦ ក្នុងកាសែតកម្ពុជា លេខ៤៧៧ ចុះថ្ងៃទី២១ខែវិច្ឆិកា មានដំណឹងខ្លីមួយក្នុងផ្នែកដំណាលខ្លីៗ ចុះផ្សាយថា៖ "មានមន្ត្រីរដ្ឋបាលម្នាក់ ដើរទៅស៊ើបរឿងចោរប្លន់នៅតំបន់តាសៀវ ឃុំប្រដាក (សៀមរាប) បានឃើញប្រជាជនខ្មែរជាច្រើននាក់លាក់ខ្លួននៅក្នុងផ្ទះបញ្ចេញតែក្បាលរហង់ មន្ត្រីនោះនឹកឆ្ងល់ក៏សួរទៅបុរសម្នាក់ដែលមានកំណាត់បាវរយ៉ែវ័ណ្ឌនៅចង្កេះថា ម្តេចក៏គេពួនដូច្នោះ? បុរសនោះឆ្លើយថា ក្នុងផ្ទះមានកន្ទបវ័ណ្ឌតែមួយ ឥឡូវខ្ញុំយកកន្ទបមកវ័ណ្ឌខ្លួនខ្ញុំទៅហើយ មនុស្សឯទៀតក៏តោងនៅលាក់ខ្លួនក្នុងផ្ទះទៅ"។

រឿងនេះមានចាស់ៗជាច្រើននៅចងចាំ ហើយពេលយើងសួរ គាត់ប្រាប់បន្ថែមទៀតថា គេមានប្រើពាក្យ "ស្លៀកពាង, ស្លៀកប៉ោត ឬស្លៀកផ្ទះ"

Most research on late 19th century and 20th century Cambodian history has concerned itself with "official" history, recording events perceived as important and focusing on leaders and rulers. If we want to know about the everyday life and experiences of ordinary people during this period, these official histories do not offer us much information. For example, when we hear elderly people talking about "wearing the water jar", "wearing the tin gas can", or "wearing the house", few official histories that we know of can tell us much about these habits of the early 1940s. Through our interviews with elderly people, however, we learned that these figures of speech refer to an extreme shortage of clothing during the time of Japanese occupation in World War II. At that time, some families - especially those living in remote areas of the countryside - sometimes had only one set of clothing for all members of the family to share. Thus, while one family member went out wearing that set of clothing, the rest of the family hid themselves naked in their house. If visitors came to the house, the owner of the house would only poke his head out of the door or window in order to greet the guest. Sometimes they used a tin gas can to cover themselves, or they went and sat in the water jar to hide their nudity from the person they wanted to talk to. This everyday history produced the figures of

ដោយសារនៅសម័យជប៉ុនចូលស្រុក (១៩៤៤-៤៥) អ្នកស្រុកខ្លះ ជាពិសេសអ្នកនៅតាមស្រុកស្រែក្រខ្សត់ ក្នុងមួយគ្រួសារមានខោអាវតែមួយសម្រាប់។ ម៉្លោះហើយបើមានអ្នកក្រៅមកលេងផ្ទះមានតែម្នាក់ទេដែលមានសម្លៀកបំពាក់ស្លៀកចេញមកក្រៅ ឯអ្នកដទៃទៀតត្រូវពួនក្នុងផ្ទះ ឬក្នុងពាង ឬក្នុងប៉ោតអ៊ើតតែក ទើបមានពាក្យនិយាយថា "ស្លៀកពាង ស្លៀកប៉ោត" នេះ។ យើងយល់ច្បាស់ថា ពាក្យស្លៀកពាងស្លៀកប៉ោតនេះ និងរឿងរ៉ាវយ៉ាងច្រើនទៀត ដែលកើតឡើងក្នុងសង្គមខ្មែរនឹងលោយសាបសូន្យអស់ក្រោយពេលមនុស្សចាស់ៗដែលធ្លាប់ឆ្លងកាត់សម័យកាលនោះចាកលោកអស់ទៅ។ ហេតុដូច្នេះហើយ ដើម្បីប្រមូលពត៌មានទាំងអស់នោះ ទើបយើងធ្វើការសម្ភាសន៍មនុស្សចាស់ៗ ដែលមានអាយុច្រើន (ចាប់ពីអាយុ៦០ឆ្នាំឡើង) ពីព្រោះគាត់អាចចងចាំរឿងផ្ទាល់របស់គាត់ផង និងចាំរឿងរ៉ាវដែលឪពុកម្ដាយគាត់បាននិយាយប្រាប់ថែមទៀតផង។ មានសេចក្ដីថា យើងអាចកំណត់បានរយៈពេលដែលគាត់ចងចាំនោះសំដៅលើពេលវេលាពីចុងសតវត្សទី ១៩ រហូតមកដល់បច្ចុប្បន្ន។

នៅស្រុកខ្មែរគេគ្មានទម្លាប់សរសេរទុកជាឯកសារនូវរឿងរ៉ាវដែលកើតឡើងជុំវិញខ្លួននោះទេ គឺគេចូលចិត្តនិយាយប្រាប់កូនចៅតៗគ្នា។ នេះដោយសារកាលៈទេសៈនៃនយោបាយក្នុងស្រុក (ដូចសម័យប៉ុល ពតជាដើម) ទើបធ្វើឲ្យការសម្ភាសន៍

speech which we still hear the elderly using - "the era when we wore the water jar, wore the gas can, or wore the house." Such details of life in Cambodian society will die with the elderly people who experienced them. Our project, The Memory Bank, aims to collect such local everyday histories.

Over the last two years, we have interviewed many elderly people over the age of sixty, both about their own experiences, and about their memories of events and experiences which their parents and grandparents told them when they were little. Thus the horizon of their memory stretches back over the 20th century to the end of the 19th century.

It is not generally a habit in Cambodian culture to write down records of the everyday experiences which unfold around us. Instead, lived experiences are told orally, passed down from generation to generation by telling. Recent events, such as the Khmer Rouge Regime and the ongoing political uncertainties, have made interviewing people and asking questions about the past more difficult, since the elderly are often afraid. Society as a whole does not necessarily value the details of the lives of ordinary people, and memories seem only to be told (often in abbreviated form) to grandchildren or small circles of relatives or friends. Young people are not necessarily

និងសាកសួរនោះមានការលំបាក ដោយមនុស្សចាស់ទូទៅគេភ័យខ្លាច។ មួយវិញទៀត គេមិនសូវមានទម្លាប់និយាយវែកញែករឿងនោះឲ្យបានក្បោះក្បាយក្រៅពីនិយាយប្រាប់បន្តិចបន្តួចដល់កូនចៅ និងញាតិមិត្តរបស់គាត់ឡើយ។ ក្មេងក៏គ្មានទម្លាប់សួរមនុស្សចាស់នូវរឿងបែបនោះដែរ។ ការងារដែលយើងធ្វើនេះហាក់ដូចជាប្លែកសម្រាប់មនុស្សចាស់ៗទាំងនោះដែលធ្វើឲ្យគេប្រុងប្រយ័ត្នក្នុងការនិយាយ។ ម្ល៉ោះហើយយើងខិតខំស្វែងរកវិធីផ្សេងៗ ដើម្បីធ្វើឲ្យគេទុកចិត្ត និងត្រូវប្រើពេលវេលាច្រើនដើម្បីសាកសួរគាត់និយាយឲ្យបានក្បោះក្បាយដោយមានថតវីដេអូនិងសំឡេងផង។ ក្រោយពីការសម្ភាសន៍អស់រយៈពេល២ឆ្នាំកន្លងមក យើងឃើញមានផុសចេញនូវរឿងរ៉ាវ ឬពត៌មានច្រើនដែលយើងមិនបានស្មានទុកជាមុនដែលអាចប្រមូលផ្តុំមកធ្វើជាប្រធានបទអ្វីមួយ។



រូបលេខ ១៖ សម្ភាសន៍លោកតាហង់ ភួង អាយុ៩៤ឆ្នាំ នៅខេត្តកណ្តាល ឆ្នាំ២០០២។ (រូបថត៖ រ៉ៃយំ)

Figure 1: Interviewing Hong Phuong, 94 years old, in Kandal Province, 2002. (Photo: Reyum)

accustomed to asking the elderly about their experiences. Given this context, our interview project often seemed strange at first to our elderly interviewees, and they were sometimes cautious or even hesitant to speak. We had to seek ways to make them trust us, and we spent long periods of time with them so that they would agree to be interviewed in detail on video and tape. After conducting these interviews for more than two years now, we have gathered a wealth of information which we never imagined when we began. Many possible themes and topics have emerged from our interviews.

Clothing and the care of the self is one of these topics which we choose to elaborate here as a catalogue and exhibition. Through detailed interviews, we tried to illuminate habits of clothing and the care of the self from the late 19th century to the 20th century, recording some traditional forms of clothing and ways of caring for the body which are virtually forgotten today, while also charting changes in clothing and makeup which occurred in the region today known as Cambodia during the late 19th century and the early 20th century. Up to the end of the 19th century, local people seem to have generally used and exchanged things made from the natural environment which surrounded them. For example, villagers burned the wood of the *pti* tree, the skins of



រូបលេខ ២៖ ម្ចាស់ក្សត្រី និងបុត្រីពីរអង្គ ស្លៀកពាក់របៀបប្រពៃណី ថតឆ្នាំ១៨៦៦ឬ៧៨ ដោយ Gsell។ (រូបថត៖ បណ្ណសារដ្ឋានជាតិ)

Figure 2: The Queen of Cambodia with her two daughters wearing traditional Khmer clothing. Photographed 1866 or 1878 by Gsell. (Photo: National Archives of Cambodia)



រូបលេខ ៣៖ ម្ចាស់ក្សត្រី ទ្រង់សម្លៀកបំពាក់របៀបបារាំង ថតឆ្នាំ ១៨៦៦ឬ១៨៧៨ ដោយ Gsell។ (រូបថត៖ បណ្ណសារដ្ឋានជាតិ)

Figure 3: The Queen of Cambodia wearing French clothing. Photographed 1866 or 1878 by Gsell. (Photo: National Archives of Cambodia)

"ស្លៀកពាក់ និងថែរក្សាខ្លួន" ដែលយកមកបោះផ្សាយជាសៀវភៅ គឺជាប្រធានបទមួយក្នុងចំណោមប្រធានបទជាច្រើនទៀត ដែលយើងសាកល្បងយកមកធ្វើក្នុងពេលនេះ។ យើងបានសាកសួរខ្លួនឯងថា បើសិនជាយើងពឹងផ្អែកទៅលើការចងចាំរបស់មនុស្សចាស់មួយចំនួននោះ តើយើងអាចដឹងខ្លះអំពីការវិវត្តន៍នៃសម្លៀកបំពាក់ និងការតុបតែងខ្លួនដែរឬទេ? សៀវភៅនេះចាត់ទុកជាការសាកល្បង

bananas, and the *ko* tree seed in order to make *kbong* water used for washing both clothing and hair. Such habits gradually changed, however, as people increasingly looked to what they perceived as the modern, and came to rely on store-bought manufactured products such as shampoo and soap. The shift to a consumer society, and the influx of Western influences, accelerated in the early 20th century when the region today known as

ឆ្លើយនឹងសំណួរខាងលើ។ ក្រោយពីសម្ភាសន៍ចាស់ៗ យើងឃើញលេចចេញនូវពត៌មានមួយចំនួនបង្ហាញអំពីសម្លៀកបំពាក់ និងរបៀបថែទាំនិងតុបតែងខ្លួន ដែលធ្លាប់មានក្នុងសង្គមខ្មែរកន្លងមក ហើយស្ទើរតែបាត់បង់អស់នាពេលសព្វថ្ងៃ។ ឧទាហរណ៍អាវបំពង់វែងនៅដើមសតវត្សទី២០ ស្ត្រីខ្មែរស្ទើរគ្រប់គ្នាពាក់ប្រចាំថ្ងៃ។ សព្វថ្ងៃនេះលែងឃើញមានពាក់ទៀតហើយ។ នេះធ្វើឲ្យយើងមានការសោកស្តាយ និងកាន់តែចង់ចងក្រងសៀវភៅនេះឲ្យចេញជារូបរាងឡើង។

រហូតមកទល់ចុងសតវត្សទី១៩ខ្មែរនៅមានទម្លាប់ច្នៃធម្មជាតិជុំវិញខ្លួនសម្រាប់យកមកប្រើប្រាស់ និងដោះដូរគ្នាទៅវិញទៅមក។ ឧទាហរណ៍មានយកដើមផ្ដី, សម្បកចេក, សម្បកផ្លែត ។ល។ មកដុតយកផេះទៅធ្វើជាទឹកក្បុងសម្រាប់កក់សក់ ឬយកល្មៀតមកធ្វើជាម្សៅលាបខ្លួន។ ទំនៀមបែបនេះបាត់បង់ និងកែប្រែបន្តិចម្តងៗទៅតាមការវិវត្តន៍ទៅរក "ភាពទំនើប" នៃសង្គម។ នៅដើមសតវត្សទី២០ ល្បឿននៃការផ្លាស់ប្តូរ និងទទួលឥទ្ធិពលពីអឺរ៉ុបកាន់តែមានសន្ទុះលឿន។ ឯការជះឥទ្ធិពលបែបអឺរ៉ុបនេះធ្វើឲ្យមានការផ្លាស់ប្តូរទាំងផ្នែកម៉ូតសម្លៀកបំពាក់ ទំនៀមទម្លាប់នៃការស្លៀកពាក់ របៀបកាត់ដេរ និងប្រភេទក្រណាត់ជាដើម។ អ្នកខ្លះនៅស្លៀកពាក់តាមរបៀបខ្មែរ ខ្លះស្លៀកជារបៀបខ្មែរផងបារាំងផង និងខ្លះទៀតស្លៀករបៀបបារាំងទាំងស្រុង។ ការផ្លាស់ប្តូរនេះមុនដំបូងឃើញថាមានទំនាស់ខ្លះដែរ ដោយអ្នកខ្លះយល់ថាល្អ អ្នកខ្លះ

Cambodia was under a French Protectorate. Outside influences affected not only types of clothing and habits of dress, but also ways of making clothing and the types of cloth used to make clothing. As the 20th century proceeded, some people continued to wear traditional types of clothing, others began to wear local styles of clothing mixed with French clothing, while still others wore only French clothing. This transition was complex and controversial since some people viewed the changes as good, modern, and *civilisé*, while others - particularly the elderly - decried the changes and viewed them as destroying Khmer traditions. Still societal change proceeded and many of these changes (such as wearing shoes and dressing in Western style clothing) have today become habits of the Cambodian people.

In addition to our research on clothing and ways of making clothing, we have included information on what we call the care and decoration of the self. By this we mean the ways in which people took care of their bodies and made them attractive to others. We have not been able to research this topic in detail, but we present here some of the things that we learned through our interviews.

Many of the problems affecting research on Cambodian history in general affected our research on clothing and the care



រូបលេខ ៤៖ កូនសិស្សខ្មែរទៅសិក្សានៅប្រទេសបារាំង ថតឆ្នាំ ១៩១៦។ (រូបថត៖ បណ្ណសារដ្ឋានជាតិ )

Figure 4: Khmer students going to France to study. Photographed 1916. (Photo: National Archives of Cambodia)



រូបលេខ ៥៖ សិស្សសាលាដែលជាខ្សែរាជវង្សខ្មែរ ថតដើមសតវត្សទី២០។ (រូបថត៖ បណ្ណសារដ្ឋានជាតិ )

Figure 5: Children of the extended royal family. Photographed at their school at the beginning of the 20th century. (Photo: National Archives of Cambodia)

ទៀត ជាពិសេសមនុស្សចាស់ៗ គាត់គិតថាមិនល្អ ប្រាសចាកទំនៀមទម្លាប់ខ្មែរ។ តែក្រោយមកបានក្លាយជារឿងធម្មតាទៅវិញ។ សម្លៀកបំពាក់ខ្លះសព្វថ្ងៃបានទៅជាទំនៀមទម្លាប់ទៅហើយ។

ក្រៅពីការសិក្សាអំពីប្រភេទសម្លៀកបំពាក់ យើងក៏ចាប់អារម្មណ៍ និងធ្លៀតបញ្ចូលជំពូកផ្សេងមួយទៀត ស្ដីពីការតុបតែងខ្លួន ពោលគឺទាក់ទងនឹងការថែរក្សាខ្លួនផង និងសម្រស់ផង។ តែយើងមានការសោកស្ដាយដែលមិនមានពេលវេលាគ្រប់គ្រាន់ដើម្បីសិក្សាអំពី មួក គ្រឿងអលង្ការជាដើម ដែលទាំងនេះយើងយល់ថា មានទាក់ទងនឹងភាពស្អាតរបស់មនុស្សដែរ។

ការរាវរកប្រវត្តិសម្លៀកបំពាក់ ក៏ដូចជាការរាវរកប្រវត្តិអ្វីៗទូទៅក្នុងអារ្យធម៌ខ្មែរដែរ។ នៅមុន "សម័យទំនើប" (សតវត្សទី១៩ដល់បច្ចុប្បន្ន) អ្វី

of the self as well. There is no one who can tell us about the period prior to the end of the 19th century. We can only rely on the little that inscriptions, temple reliefs, and other documents tell us. Chinese reports, like the one written by Chou Ta-Kuan (on his 13th century visit to the region today known as Cambodia), mention clothing briefly. We cannot however definitively say what local inhabitants wore at that time. There are even fewer sources of information about clothing during the Middle Period (the 15th to 18th centuries). Some foreign visitors (Portuguese, Spanish and Dutch) came to the area, and their clothing and habits may have had some influence, although we have no proof of this. For the period after the French established

ដែលពាក់ព័ន្ធនឹងប្រធានបទនេះ គ្មានមនុស្សណាម្នាក់ ដែលអាចឲ្យយើងសាកសួរបានឡើយ គឺមានតែពឹងផ្អែកលើពត៌មានតិចតួចពីសិលាចារឹក ចម្លាក់នៅលើប្រាសាទ ព្រមទាំងឯកសារខ្លះទៀត ដូចជារបាយការណ៍របស់លោកជីវតាក្វាន់ ដែលបានមកស្រុកខ្មែរនៅឆ្នាំ១២៩៦ជាដើម បានសរសេរខ្លះពីរបៀបស្លៀកពាក់។ ទោះជាយ៉ាងណាក៏យើងមិនអាចសន្មត់ថាដើមឡើយខ្មែរស្លៀកពាក់បែបណានោះទេ។ មកដល់ "សម័យកណ្តាល" (សតវត្សទី១៥ដល់១៨) ប្រភពពត៌មានអំពីការស្លៀកពាក់កាន់តែខ្សត់ខ្សោយណាស់ទៅទៀត។ ក្នុងអំឡុងពេលនោះមានពួកបរទេស ដូចជាព័រទុយហ្គេ អេស្ប៉ាញ និងហូឡង់ជាដើម បានចូលមកស្រុកខ្មែរ ច្បាស់ជាមានទំនាក់ទំនងគ្នាទៅវិញទៅមក។ ក្នុងនោះអាចមានទទួលឥទ្ធិពលខ្លះខាងសម្លៀកបំពាក់ផងដែរ។ ចាប់ពីមានអាណាព្យាបាលបារាំងមក មានឯកសារច្រើនជាងមុន ដូចជារបាយការណ៍រដ្ឋបាលអាណាព្យាបាលបារាំង, រូបថត ទស្សនាវដ្តី ព្រមទាំងមានមនុស្សចាស់ជាច្រើនដែលនៅចងចាំអាចឲ្យយើងសាកសួរបាន។ ក្នុងពេលនោះឥទ្ធិពលបារាំងលើផ្នែកសម្លៀកបំពាក់ និងការតុបតែងខ្លួនបានជ្រៀតចូលបន្តិចម្តងៗ និងរីករាលដាលពីទីក្រុងរហូតដល់ជនបទ។ ក្នុងអំឡុងពេលពីចុងទសវត្ស ១៩៣០ ដល់ដើមទសវត្ស១៩៤០ ជារយៈពេលមួយដែលស្រុកខ្មែរជួបប្រទះភាពក្រខ្សត់គ្រប់បែបយ៉ាង។ ក្នុងរយៈពេលនោះរបស់របរមកពីក្រៅក៏ពុំមាននាំចូល

their Protectorate in 1863, more information becomes available to us in the form of official reports, photographs, magazines, newspapers, and especially the many elderly people who still remember that time.

During the Protectorate, French clothing and habits of caring for and decorating the self entered Cambodia little by little. Such influences spread out from urban areas into the countryside. The late 1930s and early 1940s were a particularly difficult period for Cambodia. Due to World War II, trade was cut off, few goods entered the country, and there was virtually no cloth for sale in the markets. Most of our elderly interviewees called this period, "The time when the Japanese entered the country." At that time, people with money bought up cloth and stored it so that they could make clothing. Others, like Khlot Samol, did not do so. She told us, "At that time, the wings of planes were made from thick canvas. I ripped cloth from the wings of a broken plane that the Japanese had abandoned on a path in the forest. I used that canvas to make clothes to wear." Many others used the fibers of the *ko* tree seed to weave cloth and make clothing. Seeds of the *ko* tree were easy to find, but the cloth woven from their fibers was not nearly as good as that made from cotton. At that time, French officials confiscated any cloth which they saw being woven out of cotton.

សូម្បីនៅតាមផ្សារក៏គ្មានក្រណាត់លក់ដែរ។ បើស្តាប់តាមមនុស្សចាស់និយាយ ភាគច្រើនគាត់ហៅសម័យនោះថា "សម័យជប៉ុនចូលស្រុក"។ ក្នុងសម័យនោះ អ្នកខ្លះមានលុយគេទិញបានក្រណាត់ទុក អាចមានខោអាវស្លៀកពាក់ខ្លះ អ្នកខ្លះទៀត ដូចជាលោកយាយខ្ចូត សំអុល និយាយថា "ពីជំនាន់នោះស្លាបកប៉ាល់ហោះ (យន្តហោះ) ធ្វើពីក្រណាត់ក្រាស់ៗ ខ្ញុំទៅហែកក្រណាត់នោះពីកប៉ាល់ហោះខូច ដែលពួកជប៉ុនបោះចោលនៅច្រងាងក្នុងព្រៃ ខ្ញុំបានក្រណាត់នោះហើយយកមកកាត់ខោអាវស្លៀក"។ ចំពោះអ្នកមួយចំនួនធំទៀត គេយកសំឡីតត្បាញជាក្រណាត់ធ្វើជាសម្លៀកបំពាក់។ សំឡីតងាយស្រួលរក តែក្រណាត់ដែលធ្វើពីសំឡីតពុំមានគុណភាពល្អដូចធ្វើពីសំឡីកប្បាសឡើយ។ ក្នុងពេលនោះដែរ បើអ្នកណាយកសំឡីកប្បាសត្បាញ ហើយរាជការបារាំងឃើញត្រូវរឹបអូសយកក្រណាត់ដែលកំពុងត្បាញតែម្តង។ លើសពីនេះ បារាំងបានបង្ខំឲ្យប្រជាជនលក់សំឡីកប្បាសឲ្យបារាំងថែមទៀត ដែលផ្ទុយស្រឡះពីមុនពេលមានសង្គ្រាម ស្ទើរគ្រប់ក្រុមគ្រួសារគេដាំកប្បាស និងត្បាញក្រណាត់សម្រាប់ប្រើប្រាស់ដោយខ្លួនឯង ឬសម្រាប់ដោះដូរខ្លះៗ។ យើងមិនហ៊ានអះអាងច្បាស់ថា បារាំងធ្វើយ៉ាងនេះ ដោយសារចង់លុបបំបាត់ទំនៀមត្បាញជាលក្ខណៈគ្រួសារ ដោយបង្កើតទៅជាឧស្សាហកម្មរបៀបសហគមន៍មួយវិញ ឬក៏មូលហេតុចង់ឲ្យខ្មែរប្រើក្រណាត់របស់បារាំងនាំចូលមកនោះទេ។

These officials pressured farmers to sell their raw cotton to France. This was completely different from the period preceding the war when almost every local family grew some cotton and wove cloth from it for their own use and sometimes for small scale exchange. We do not know whether the French policy was initiated in order to destroy family weaving, to begin a cooperative industry, or to force local populations to buy imported French cloth. There is not yet enough clear information about this policy to judge it. The war years were chaotic and complex with the French administration still ruling for most of the period under a Japanese military occupation. We do know, however, that due to the lack of both clothing and soap (which was very expensive if it was available at all), many people became infected with a type of skin-burrowing flea which was tiny and white. These dire conditions lasted only for a year or so. After the war ended, conditions improved somewhat and goods began to enter the country again little by little.

After independence, Cambodians had the freedom to rule and develop their country as they wished. Perhaps because the Sangkum Reastr Niyum Government wanted to decrease the country's dependence on imported goods, its policies emphasized the development of domestic industrial production, particularly factories and

ទោះជាយ៉ាងណាក៏យើងពុំមានពត៌មានស្តីពីរឿងនេះច្បាស់ដែរ ហើយពេលនោះជារយៈកាលមួយដូចជាច្របូកច្របល់ដែរ ដែលមានបារាំងកំពុងគ្រប់គ្រងស្រុកផង និងមានជប៉ុនចូលមកទៀត ដូច្នេះយើងពិបាកក្នុងការសន្និដ្ឋានណាស់។ មិនតែប៉ុណ្ណោះក្នុងសម័យនោះខ្វះគ្មានខោអាវផ្លាស់ប្តូរ ហើយសាប៊ូក៏មានតម្លៃថ្លៃទៀតធ្វើឲ្យមនុស្សភាគច្រើនកើតជំងឺចៃចេញពីសាច់ (ជាសត្វល្អិតតូចៗ ពណ៌ស កើតចេញពីស្បែក)។ តែការខ្វះខាតនេះមានរយៈប្រហែលជាមួយឆ្នាំប៉ុណ្ណោះ បន្ទាប់ពីចប់សង្គ្រាមលោកលើកទី២ បានធូរស្រាលឡើងជាបន្តបន្ទាប់ ការនាំចូលរបស់របរក៏មានជាបណ្តើរៗឡើងវិញដែរ។ ក្រោយពីទទួលបានឯករាជ្យ ខ្មែរមានសេរីភាពពេញលេញធ្វើជាម្ចាស់ស្រុក និងអាចអភិវឌ្ឍន៍ប្រទេសរបស់ខ្លួនដោយខ្លួនឯង។ ប្រហែលជាមកពីរបបសង្គមរាស្ត្រនិយមចង់កាត់បន្ថយទំនិញនាំចូលមកពីបរទេសខ្លះ ហើយដើម្បីអភិវឌ្ឍន៍ប្រទេសឲ្យកាន់តែសម្បូណ៌នោះ ទើបមានបង្កើតឧស្សាហកម្មច្រើននៅក្នុងស្រុក ពិសេសរោងសិប្បកម្មត្បាញសូត្រ និងក្រណាត់ដែលផលិតផលទាំងអស់នោះមិនត្រឹមតែបំពេញសេចក្តីត្រូវការគ្រប់គ្រាន់ក្នុងស្រុកប៉ុណ្ណោះទេ ថែមទាំងនាំយកទៅលក់នៅប្រទេសក្រៅទៀតផង។ យើងនិយាយនេះមិនមែនបានន័យថា មានតែផលិតផលក្រណាត់ឡើយដែលនាំចេញ សូម្បីសំឡីកប្បាស រួមទាំងផលិតផលបានពីវិស័យកសិកម្មច្រើនទៀតក៏មាននាំចេញដែរ។

artisanal industries weaving silk and cloth. This silk and cloth production was intended not only to fill domestic demand, but also to be exported abroad. In addition to cloth, raw cotton and other agricultural products began to be exported.

During the Sangkum Reastr Niyum Period, the population was encouraged to modernise and, in terms of clothing, came to particularly embrace modern French fashions. Printed materials, such as the magazine *Our Village*, tried to show rural inhabitants how to dress and present themselves. As the magazine explained, "Before, men and women in our village did not know how to dress and make themselves up. Many women tied their hair back in buns and wore *sampot* wrapped so that their belly buttons were exposed. Sometimes they didn't even close their buttons!" Such habits of wearing clothing were considered inappropriate. In cities, decrees were issued ordering people to dress properly when they went to the markets or used public places. Even just to go outside one's home, the new decrees explained, one should not wear just a *krama* or a *sarong*. While such new decrees had some effect on city dwellers, they were generally ineffectual in the face of long-standing traditions and habits of dressing among the predominantly rural population as a whole. Some people embraced such new and modern notions,

បើនិយាយពីការស្លៀកពាក់ របបសង្គមរាស្ត្រនិយមហាក់ដូចជាចង់ឲ្យប្រជាពលរដ្ឋឈានទៅរកភាពទំនើបមួយតាមអារ្យធម៌បរទេស ពិសេសបារាំង។ ឧទាហរណ៍ មានទស្សនាវដ្តីមួយឈ្មោះ "ភូមិយើង" បានចុះផ្សាយអប់រំពីការស្លៀកពាក់តុបតែងខ្លួនដល់អ្នកជនបទ ដោយគេបានសរសេរថា "ពីដើមប្រុសស្រីទូទៅនៅភូមិយើង មិនចេះស្លៀកពាក់ ធ្វើខ្លួនទេ បើស្រីវិញ ច្រើនបួងសក់ពីក្រោយ ស្លៀកសំពត់សំយេះក្បាលពោះនៅទទេ ហើយថែមទាំងមិនបិទឡេវផង"។ ចំណែកនៅទីក្រុងឃើញមានចេញសេចក្តីប្រកាសឲ្យមនុស្សទូទៅក្នុងស្រុកស្លៀកពាក់ឲ្យ

while others found them destructive and bad. In particular, people living in the countryside were used to wearing *krama* and *sarong*, and did not alter such habits easily. Today, we still see people wearing *krama* and *sarong* in a way which the 1950s decrees wished to end.

Our research has relied almost entirely on interviewing elderly people. Our particular topic here - clothing and the care of the self - draws more on our interviews with elderly women than with elderly men, since this topic has traditionally played a greater role in the lives of women than in the lives of men. Our interviewees have provided us with



រូបលេខ ៦៖ ការគូរបង្ហាញរបៀបស្លៀកពាក់ឲ្យសមរម្យ។ ស្រង់ចេញពីទស្សនាវដ្តី "ភូមិយើង" ចុះខែមករា ឆ្នាំ១៩៦១។

Figure 6: A drawing contrasting proper and improper dress from *Our Village*, January 1961.



រូបលេខ ៧៖ នារីបម្រើលើយន្តហោះ ក្រុមហ៊ុនអាកាសចរណ៍ភូមិន្ទកម្ពុជា ស្លៀកពាក់ឯកសណ្ឋានបែបខ្មែរ (ខាងឆ្វេង) និងបែបទំនើប (ខាងស្តាំ)។ ថតទសវត្ស១៩៦០។ (រូបថត៖ ដកស្រង់ពីទស្សនាវដ្តីអាកាសចរណ៍ភូមិន្ទកម្ពុជា ឆ្នាំ១៩៩៧។)

Figure 7: Royal Air Cambodge staff. The stewardesses wear (left) traditional Khmer and (right) more modern uniforms. Photographed in the 1960s. (Photo: RAC Magazine, 1997)

បានសមរម្យពេលចេញដើរតាមផ្សារ ឬទីសាធារណៈផ្សេងៗ សូម្បីតែចេញទៅក្រៅរបងផ្ទះក៏ដោយ ក៏មិនត្រូវស្លៀកក្រមា ឬសារុងឡើយ។ ការចេញច្បាប់រឿងស្លៀកពាក់នេះ ទោះជាបានជ្រាបចូលខ្លះចំពោះអ្នកទីក្រុងក៏ដោយ តែក៏មានផលប៉ះពាល់ខ្លះៗទៅលើទម្លាប់ស្លៀកពាក់របស់គេពីមុនមកដែរ បានន័យថា អ្នកខ្លះគេពេញចិត្តយកភាពទំនើបនេះ អ្នកខ្លះទៀតគេយល់ថាភាពទំនើបមិនល្អទៅវិញ។ ជាពិសេសចំពោះអ្នកស្រុកស្រែ បើនិយាយពីការស្លៀកសារុង ក្រមា ក្លាយជាទម្លាប់មួយដែលមិនងាយនឹងចោលបាន។ រហូតដល់សព្វថ្ងៃ ការស្លៀកសារុង ក្រមានៅតែមានដែរ។

ក្នុងការស្រាវជ្រាវនេះ យើងផ្តោតសំខាន់ទៅលើប្រភពពត៌មានបានមកពីការសាកសួរមនុស្សចាស់ៗ។ ពត៌មានទាក់ទងទៅនឹងប្រធានបទដែលយើងកំពុងធ្វើនេះភាគច្រើនទទួលបានពីមនុស្សស្រី ពីព្រោះរឿងរ៉ាវទាំងអស់នោះទាក់ទងនឹងជីវិតមនុស្សស្រីច្រើនជាងបុរស។ ជួនកាលពួកគាត់ផ្តល់ទាំងរូបថតចាស់ៗដែលសេសសល់តាំងពីជំនាន់មុន ព្រមទាំងគូរបង្ហាញជារូបប្រភេទសម្លៀកបំពាក់ដែលគាត់ធ្លាប់ប្រើតាំងពីក្មេងរហូតមក។

ឆ្លៀតក្នុងឱកាសនេះ យើងខ្ញុំសូមថ្លែងអំណរគុណដល់លោកតា លោកយាយទាំងអស់ដែលបានផ្តល់ពេលវេលាក្នុងការសំណេះសំណាល និងសាកសួរ។ យើងខ្ញុំសូមអភ័យទោសដែលមិនបានរាយឈ្មោះអស់ ដោយលើកយកតែឈ្មោះលោកតា

old photographs which they have saved from the past. They have also drawn pictures of the types of clothing they wore when they were little.

We would like to thank the many elderly people who took the time to be interviewed and answered our questions patiently. We apologize that we cannot include all their names in the text that follows. We thank the following institutions for generously allowing us to access and use




រូបលេខ ៨៖ សម្លៀកបំពាក់ទំនើប បង្ហាញលើគ្របទស្សនាវដ្តីលោកសេរី បោះពុម្ពក្នុងទសវត្ស១៩៥០។ (ក្បាលទី៥, លេខ២)

Figure 8: Modern fashion presented on the cover of the United States Information Service magazine *Lok Serei* (*Free World*) published in the 1950s (vol. 5, #2).

លោកយាយខ្លះដែលយកមកប្រើក្នុងសៀវភៅនេះតែប៉ុណ្ណោះ។ យើងខ្ញុំក៏សូមថ្លែងអំណរគុណដល់ស្ថាប័នផ្សេងៗ ដូចជាបណ្ណាល័យជាតិ, បណ្ណសារដ្ឋានជាតិ, បណ្ណាល័យសារមន្ទីរជាតិ, វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ, បណ្ណាល័យមហាវិទ្យាល័យបុរាណវិទ្យា, មជ្ឈមណ្ឌលឯកសារកម្ពុជា, បណ្ណាល័យកណ្ដាលក្រសួងអប់រំជាដើម ដែលជួយផ្ដល់ឯកសារក្នុងការស្រាវជ្រាវ។

ម្យ៉ាងទៀតសូមថ្លែងអំណរគុណចំពោះលោក អាំង ជូលាន, ម៉ៃខឹល វិកខឺរី ដែលបានផ្ដល់យោបល់ និងជួយជាគំនិតក្នុងការនិពន្ធ។ ក្នុងឱកាសនេះដែរ យើងខ្ញុំសូមថ្លែងអំណរគុណដល់លោកលី តារាវុធ និងលោកស្រីអ៊ីនគ្រីដ មូអាន់ ដែលបានណែនាំនិងបង្ហាត់បង្រៀនកិច្ចការស្រាវជ្រាវ ព្រមទាំងបណ្ដុះបណ្ដាលយើងខ្ញុំ។ ម្យ៉ាងទៀត ក៏សូមអរគុណដល់បុគ្គលិករៃយំទាំងអស់ដែលបានជួយក្នុងការងារនេះ។

ជាទីបញ្ចប់ យើងខ្ញុំសូមថ្លែងអំណរគុណដល់មូលនិធិដែលបានផ្ដល់ជំនួយថវិកាសម្រាប់ការស្រាវជ្រាវ និងបោះពុម្ពសៀវភៅនេះគឺ៖ មូលនិធិរ៉ុកហ្វែល័រ, មូលនិធិ កាស៊ុមីស៊ូ, មូលនិធិ គ្រួសារអាល់ប៊ែរ ឃុនស្តាតធ័រ។

their documents: the National Library of Cambodia, the National Archives of Cambodia, the library of the National Museum of Cambodia, the Buddhist Institute, the library of the Royal University of Fine Arts, the Documentation Center of Cambodia, and the Banneahoc Library of the Ministry of Education. We thank Dr. Ang Choulean and Dr. Michael Vickery for advising us and providing ideas for this project. We also wish to thank Ly Daravuth and Dr. Ingrid Muan for advising, supporting and helping us in realising this project. We thank all of the Reyum staff as well for their help and commitment to our project.

This project was funded by the Rockefeller Foundation with additional support provided by the Kasumisou Foundation and the Albert Kunstadter Family Foundation. We thank these Foundations for their generous support which has enabled us to pursue and publish this research. Any mistakes or confusing passages are of course our own responsibility and we hope that readers will take this book as an invitation to do more research on the topics sketched here.